- បានឃើញព្រះរាជក្រមលេខ នស./រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តី
ការបង្កើតក្រសួងមហាផ្ទៃ

- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា ១** .- ត្រូវបានបង្កើតស្រុកសំឡូត ។

**មាត្រា ២** .- ស្រុកសំឡូត ត្រូវស្ថិតក្រោមការគ្រប់គ្រងរដ្ឋបាលរបស់ខេត្តបាត់ដំបង ។

**មាត្រា ៣** .- ស្រុកសំឡូត ត្រូវបានបង្កើតឃុំចំនួន ០៦ ចំណុះ គឺឃុំតាតោក ឃុំកំពង់ល្ពៅ ឃុំអូរសរិ
ឃុំស៊ុង ឃុំសំឡូត និងឃុំមានជ័យ ។

**មាត្រា ៤** .- ស្រុកសំឡូតត្រូវបានកំណត់ព្រំប្រទល់រដ្ឋបាលដូចខាងក្រោម :

- ខាងជើងទល់នឹងព្រំប្រទល់ក្រុងប៉ៃលិន និងស្រុករតនមណ្ឌលខេត្តបាត់ដំបង
- ខាងត្បូងទល់នឹងព្រំប្រទល់ស្រុកវាលវែង នៃខេត្តពោធិសាត់ ។
- ខាងកើតទល់នឹងព្រំប្រទល់ស្រុកបាណន់ នៃខេត្តបាត់ដំបង ។
- ខាងលិចទល់នឹងព្រំប្រទល់ ព្រះរាជាណាចក្រថៃឡង់ដ៏ ។

**មាត្រា ៥** .- ទីតាំងសាលាស្រុកសំឡូត ស្ថិតនៅក្នុងឃុំស៊ុង ។

**មាត្រា ៦** .- បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៧** .- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេ
ធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋានត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេ
តទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

* * *

## អនុក្រឹត្យ លេខ ៣៦ អនក្រ.បក

## ស្តីពីការបង្កើតស្រុកសំពៅលូន ចំណុះខេត្តបាត់ដំបង

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស./រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

មាត្រា ១ .. ត្រូវបានបង្កើតស្រុកសំពៅលូន ដោយកាត់យកភូមិសាស្ត្រមួយចំណែកពី ខេត្តបន្ទាយមានជ័យ ។

មាត្រា ២ .. ស្រុកសំពៅលូន ត្រូវស្ថិតក្រោមការគ្រប់គ្រងរដ្ឋបាលរបស់ខេត្តបាត់ដំបង ។

មាត្រា ៣ .. ស្រុកសំពៅលូនត្រូវបានបង្កើតឃុំចំនួន ០៦ ចំណុះ គឺ ឃុំសំពៅលូន ឃុំអង្គរបាន ឃុំតាស្តា ឃុំសន្តិភាព ឃុំសិរីមានជ័យ ឃុំជ្រៃសីមា ។

មាត្រា ៤ .. ស្រុកសំពៅលូនត្រូវបានកំណត់ព្រំប្រទល់រដ្ឋបាលដូចខាងក្រោម :

- ខាងជើងទល់នឹងព្រំប្រទល់ស្រុកម៉ាឡៃ នៃខេត្តបន្ទាយមានជ័យ ។
- ខាងត្បូងទល់នឹងព្រំប្រទល់ក្រុងភ្នំព្រឹក នៃខេត្តបាត់ដំបង ។
- ខាងកើតទល់នឹងព្រំប្រទល់ស្រុកបវេល នៃខេត្តបាត់ដំបង ។
- ខាងលិចទល់នឹងព្រំប្រទល់ ព្រះរាជាណាចក្រថៃឡង់ដ៏ ។

មាត្រា ៥ .. ទីតាំងសាលាស្រុកសំពៅលូន ស្ថិតនៅក្នុងឃុំតាស្តា ។

មាត្រា ៦ .. បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវជានិរាករណ៍ ។

មាត្រា ៧ .. សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

* * *